# នានាភាពនៃកុលាលភាជន៍ខ្មែរសម័យអង្គរ (ភាគ៣)

នានាភាពនៃកុលាលភាជន៍ គឺមានន័យសំដៅទៅលើប្រភេទឬរូបរាងផ្សេងៗរបស់ភាជន៍ ពិសេសគឺផ្តោតជាសំខាន់ទៅលើពាក្យដែលខ្មែរនាសម័យបុរាណបានប្រើប្រាស់សម្រាប់ហៅភាជន៍ដែលមានរូបរាងខុសគ្នា។ នៅក្នុងអត្ថបទទី២ ស្តីអំពីលក្ខណៈទូទៅនៃកុលាលភាជន៍ខ្មែរសម័យអង្គរ[១] ខ្ញុំបានបង្ហាញត្រួសៗរួចហើយអំពីប្រភេទ ឬរូបរាងភាជន៍ដែលយើងបានជួបប្រទះនៅតាមបណ្តាឡបុរាណមួយចំនួនក្នុងតំបន់អង្គរ និងតាមបណ្តាស្ថានីយប្រវត្តិសាស្ត្រផងដែរ។ ការសិក្សាលើរូបរាងផ្សេងៗ និងពាក្យដែលប្រើប្រាស់ទាំងនេះ គឺពឹងផ្អែកទាំងស្រុងលើសិលាចារឹកខ្មែរសម័យបុរាណ ទាំងអត្ថបទភាសាជាសំស្ក្រឹត ទាំងអត្ថបទជាភាសាខ្មែរ ដោយប្រៀបធៀបជាមួយនិងពាក្យខ្មែរបច្ចុប្បន្ន និងភាសាអំបូរមនខ្មែរមួយចំនួនផង។ ការសិក្សានេះ ខ្ញុំធ្លាប់បានសង្ខេប និងបោះពុម្ពជាភាសាអង់គ្លេសម្តងរួចមកហើយ (សូមអានពត៌មានលម្អិតក្នុងអត្ថបទជាភាសាអង់គ្លេស)។[២] ក្នុងអត្ថបទនេះ ខ្ញុំនិងលើកមកសង្ខេបជាថ្មី ជាខេមរភាសា។ ជាធម្មតា យើងសព្វថ្ងៃប្រើពាក្យសម្គាល់លើភាជន៍ដែលមានរូបរាងខុសគ្នា តែជាងដប់ពាក្យប៉ុណ្ណោះ។ ប៉ុន្តែបើពិនិត្យតាមសិលាចារឹក ឃើញថា៖ ខ្មែរបុរាណមានប្រើពាក្យប្រហែល៣៧ ទាំងភាសាសំស្ក្រឹតនិងភាសាខ្មែរ សម្រាប់ហៅភាជន៍ដែលមានរូបរាងខុសៗគ្នា។

## តើពាក្យទាំងនោះមានអ្វីខ្លះ?

ដើម្បីអោយងាយយល់ ខ្ញុំនិងរៀបតាមលំដាប់ ស្រះ និងព្យញ្ជនៈខ្មែរ ជាលំអានដូចជា៖

### ១.អ៌ឃ្យ /Arghya/

អ៌ឃ្យ គឺជាពាក្យសំស្ក្រឹតមានន័យសំដៅលើទឹកដែលរៀបចំដោយក្តីគោរពសម្រាប់ទទួលភ្ញៀវ។ វាអាចជាភាជន៍មួយប្រភេទប្រើសម្រាប់ដាក់ទឹកទទួលភ្ញៀវ។ ពេលខ្លះវាត្រូវបានប្រើជាពាក្យ អ៌ឃ្យបាទ្យ ដែលមានន័យថាភាជន៍ដាក់ទឹកលាងជើងអោយភ្ញៀវ។ យើង

---

[១] សុខ កែវ សុវណ្ណារ៉ា, (២០២១)

[២] Sok Keo Sovannara, (2007)

មិនដឹងពីរូបរាងពិតប្រាកដរបស់ភាជន៍ទេ។ ពាក្យនេះមានក្នុងសិលាចារឹកសតវត្សទី១០ ដល់ទី១២ ឧទាហរណ៍សិលាចារឹក K.754 ជាដើម។

**២.អាង** /Āṅ/ (*រូបលេខ១*)

អាងជាពាក្យខ្មែរ មានន័យជាភាជន៍មួយប្រភេទមានទំហំធំ ឬជាថាំង (ពាក្យចិន)។ វាអាចមានន័យថាជាប្រភេទពាងទឹកធំៗ។ វាអាចជាភាជន៍មានបាតតូច ក្អេងខ្ញីប៉ោងធំ និង មាត់តូច។ ខ្ញុំគិតថាភាជន៍នេះប្រហែលជាមានទំហំធំដែលអាចផ្ទុកនូវបរិមាណទឹកឬវត្ថុរាវផ្សេងៗបានច្រើន។ ពាក្យនេះមិនសូវមានច្រើនក្នុងសិលាចារឹកទេ ហើយច្រើនជាឈ្មោះរបស់មនុស្ស ឧទាហរណ៍ក្នុងសិលាចារឹក K.600 មានបុរសឈ្មោះ វា អាង។

**៣.កឋាហ/កទាហ/គទាហ** /Kaṭāha, kadāha, gadāha/ (*រូបលេខ២*)

កឋាហជាពាក្យសំស្ក្រឹតដែលមានន័យសំដៅទៅលើកំសៀវ ឬឆ្នាំងដាំទឹកមួយប្រភេទ។ វាជាភាជន៍មួយបែបមានរូបរាងជាឆ្នាំងធា ដែលភាសាខ្មែរបច្ចុប្បន្នហៅថា ខ្ទះ។ ពាក្យនេះមាននៅក្នុងសិលាចារឹកចម្ប៉ាដែរ តែសរសេរជាពាក្យ *កទាំ* ដូចនេះវាអាចមានរូបរាងជាភាជន៍មានបាទមូលក្រឡោម ក្អេងរីកធំទូលាយចេញក្រៅ។ ពាក្យនេះឃើញមានក្នុងសិលាចារឹកសតវត្សទី៩ដល់១២។

**៤.កថោរ** /Kathor/(*រូបលេខ៣*)

កថោរ ជាពាក្យខ្មែរ ដែលមានន័យសំដៅលើចានក្រឡោមខ្ពស់ ឬកន្ថោរ ជាធម្មតាច្រើនធ្វើអំពីលោហៈ។ ពាក្យនេះអាចក្លាយពីពាក្យសំស្ក្រឹត កដោរ ដែលមានន័យថាភាជន៍ ឬពែង។ វាអាចមានទំនាក់ទំនងទីនិងភាសាប្រាក្រិត *កដោរ*។ បើយើងប្រៀបធៀបមកប្រភេទកន្ថោរសព្វថ្ងៃ វាមានរូបរាងជាភាជន៍ធំល្មម មានជើងជាថ្នាក់ៗ ក្អេងប៉ោង កតូចល្មម និងមាត់បើករាចេញក្រៅ។ ពាក្យនេះមានបង្ហាញក្នុងសិលាចារឹកសតវត្សទី៩ ទី១១ និងទី១២។

**៥.កន្ទិន/ទិន** /kandin, din/(*រូបលេខ៤*)

កន្ទិន ឬទិន ជាពាក្យខ្មែរមានន័យសំដៅលើភាជន៍មានទំហំធំល្មម ជាទូទៅធ្វើពីដីដុត មានបាតតូចរាបស្មើ ក្អេងធំ និងមាត់តូចចង្អៀត។ ក្នុងសិលាចារឹកពាក្យកន្ទិនបង្ហាញជាឈ្មោះមនុស្ស ឬទីកន្លែង ពុំមានជាវត្ថុប្រើប្រាស់ទេ។

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា

៦.កន្ទោ /Kanlo/ (រូបលេខ១៥)

កន្ទោជាពាក្យបុរាណ មានន័យថាក្រឡ ដែលសំដៅទៅលើភាជន៍មានទំហំតូចល្មម ប្រើប្រាស់សម្រាប់ផ្ទុកវត្ថុផ្សេងៗ។ វាមានរាងដូចកន្ធិន តែមានទំហំតូចជាង ហើយមាត់រីកធំជាងមាត់កន្ធិន។ ក្នុងសិលាចារឹកពាក្យនេះបង្ហាញជាឈ្មោះមនុស្ស។

៧.កមណ្ឌលុ /Kamaṇḍalu/(រូបលេខ១៦)

កមណ្ឌលុ គឺជាពាក្យសំស្ក្រឹតមានន័យសំដៅទៅលើភាជន៍មួយប្រភេទ ឬជាគុមទឹកប្រើសម្រាប់ពិធីសាសនា។ ម៉្យាងទៀត វាត្រូវបានគេសម្គាល់លើភាជន៍ដែលមានរូបរាងជាឃ្មោក ឬក្រឡសម្រាប់ដាក់ទឹករបស់អ្នកបួស ឬតាបស។ ក្នុងទេវកថាឥណ្ឌា កមណ្ឌលុជាភាជន៍កាន់ដោយព្រះគណេស ជាភាជន៍សម្រាប់ស្រោចទឹក ឬជម្រះកាយ។ ពាក្យនេះមានក្នុងសិលាចារឹកសតវត្សទី១០ និងទី១២ ជាភាជន៍ធ្វើពីលោហៈ មាសជាដើម។

៨.ករង្គ /Karaṅka/ (រូបលេខ១៧)

ករង្គ ជាពាក្យសំស្ក្រឹតមានន័យសំដៅលើអ្វីដែលមានរូបរាងដូចលលាដ៍ក្បាល ឬត្រឡោកដូង។ ពាក្យនេះក្លាយពីពាក្យ ករក ជាភាជន៍ដែលប្រើដោយសិស្សឬតាបស។ សិលាចារឹកខ្មែរភាគច្រើនអធិប្បាយអំពីវត្ថុមួយមានរាងជាលលាដ៍ក្បាល ឬត្រឡោកដូង ដែលគេប្រើក្នុងពិធី។ រូបរាងដើមរបស់ភាជន៍នេះនៅមិនទាន់ដឹងច្បាស់លាស់ទេ។ ពាក្យនេះមានក្នុងសិលាចារឹកសម័យមុនអង្គរ និងអង្គរ ជាភាជន៍ធ្វើពីមាស ជួនកាលមានរាងជាខ្លួនមនុស្សឬសត្វ។

៩.កលស /Kalaśa /

កលស គឺជាពាក្យសំស្ក្រឹតមានន័យសំដៅលើភាជន៍មួយប្រភេទសម្រាប់ដាក់ទឹក។ ភាចន៍ប្រភេទនេះនៅមានប្រើប្រាស់ក្នុងប្រទេសឥណ្ឌានៅឡើយ។ វាអាចមានបាតមូល ឬមានជើងខ្ពី មានក្អេងធំ កតូចចង្អៀត និងមាត់រីកចេញក្រៅ។ ភាជន៍មួយជាកលសរបស់ចាមមានរាង៨ជ្រុង ធ្វើពីសំរឹទ្ធ និងមានសិលាចារឹកនៅលើនោះដែរ។ ពាក្យនេះមានប្រើក្នុងសម័យមុនអង្គរ និងអង្គរ។

១០. កុន្ទិ/កន្តិ/កុន្តិកា/កុន្ទក /Kunti, kanti, kuntikā, kundaka/ (រូបលេខ១៨)

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា

កុន្តិកា ជាពាក្យក្លាយពីសំស្ក្រឹតដើមហៅថា កុណ្ឌក ឬកុណ្ឌ។ ពាក្យនេះក្លាយមកជាពាក្យខ្មែរសព្វថ្ងៃ កុន្ទី ដែលសំដៅលើប្រភេទភាជន៍មានចំពួយដូចកំសៀវ។ រូបរាងរបស់ភាជន៍នេះមានបាតរាបស្មើ ជួនកាលមានជើងខ្ពី ក្អេងធំ តតូចល្មម មាត់បើករីកចេញក្រៅ និងមានចំពួយដូចកំសៀវ។ ពាក្យនេះមានបង្ហាញក្នុងសិលាចារឹកសម័យមុនអង្គរ និងអង្គរ ជាវត្ថុ ជួនកាលជាឈ្មោះរបស់មនុស្ស។

**១១. កុសុម្ភ /Kusumbha/ (រូបលេខ៩)**

កុសុម្ភជាប្រភេទភាជន៍មួយប្រើសម្រាប់ដាក់ទឹក ពេលខ្លះជាភាជន៍ប្រើដោយតាបស និងសិស្ស។ រូបរាងពិតប្រាកដរបស់ភាជន៍នេះនៅមិនទាន់ដឹងច្បាស់នៅឡើយ។ ពាក្យនេះអាចក្លាយមកជាពាក្យ កុម្ភៈ ដែលមានន័យថាក្អមទឹក។ យើងឃើញមានតែម្តងគត់ក្នុងសិលាចារឹកសតវត្សទី១៤ (K.754)។

**១២. កោស/កោឝ /Kośa, koça/(រូបលេខ១០)**

កោសជាពាក្យសំស្ក្រឹតដែលមានន័យថា ហិបឬស្រោម។ ពាក្យនេះអាចក្លាយមកពាក្យខ្មែរបច្ចុប្បន្នហៅថា កោដ្ឋ ដែលជាប្រភេទភាជន៍ប្រើសម្រាប់ដាក់ធាតុដែលបូជារួចហើយ។ ក្នុងករណីបែបនេះ កោស ជាភាជន៍មានបាតរាបស្មើ ក្អេងជាសុីឡាំងរីកធំទៅលើ និងមានគម្របផងដែរ។ ពាក្យនេះមានក្នុងសិលាចារឹកសតវត្សទី៩ដល់ទី១៣។ យើងជួបប្រទះភាជន៍ប្រភេទនេះយ៉ាងច្រើននៅតាមប្រាសាទនានា ពិសេសតាមស្ថានីយឡបុរាណក្នុងតំបន់អង្គរ។

**១៣. ក្លស/ខ្លស/ក្លាស / Klas, khlas, khlās/**

ក្លសជាពាក្យខ្មែរមានន័យសំដៅលើភាជន៍ប្រើសម្រាប់ដាក់ទឹកពិសិដ្ឋថ្វាយទេព។ វាដូចគ្នានិងភាសាមន ក្លស ដែលមានន័យថាភាជន៍ដាក់ទឹកប្រើក្នុងពិធី។ ពាក្យនេះអាចក្លាយមកពីពាក្យសំស្ក្រឹត កលស។ កលសមានតិចតួចក្នុងសិលាចារឹកសម័យមុនអង្គរ តែមានច្រើនក្នុងសិលាចារឹកសម័យអង្គរ។

**១៤. ខាល/ខល /Khāl, khal/(រូបលេខ១១)**

ខាលជាពាក្យខ្មែរ មានន័យថាជាភាជន៍មួយប្រភេទ ភាគច្រើនធ្វើអំពីលោហៈ មាស ប្រាក់ ឬទង់ដែង។ វាដូចគ្នានិងពាក្យមន ហៅថា ខល មានន័យថាពែងឬចានតូច

AMS
អរិយធម៌ខ្មែរ

សម្រាប់ដាក់ម្ហូបសែន។ ពាក្យនេះត្រូវបានជំនួសដោយពាក្យសម័យថ្មី ហៅថា ផ្តិល។ វាមិនសូវបង្ហាញក្នុងសិលាចារឹកសម័យមុនអង្គរ តែមានច្រើនក្នុងសម័យអង្គរ។

**១៥.ខ្លែង /Khleṅ/ (រូបលេខ១១២)**

ខ្លែងជាពាក្យខ្មែរមានន័យច្រើន ដូចជា៖ (១)ជាប្រភេទសត្វស្លាប (២)ជាឧបករណ៍បង្ហោះលេង និង(៣)ជាភាជន៍សម្រាប់ដាក់កំបោរក្នុងគ្រឿងរណ្តាប់ស្លាម្លូ។ នាសម័យបុរាណគេតែងប្រើពាក្យខ្លែងសំគាល់លើភាជន៍រូបសត្វសម្រាប់ដាក់កំបោរ តែបច្ចុប្បន្ន គេប្រើពាក្យអកកំបោរវិញ ត្បិតអកនិងខ្លែងមានរូបរាងដូចគ្នា។ ពាក្យនេះពុំសូវមានបង្ហាញក្នុងសិលាចារឹកទេ។

**១៦.ចាន /Cān/ (រូបលេខ១១៣)**

ចានជាពាក្យខ្មែរ ដែលមានន័យសំដៅលើភាជន៍មានរាងក្រឡោមឬសំប៉ែត ប្រើសម្រាប់ដាក់បាយ ម្ហូបជាដើម។ ពាក្យនេះមានបង្ហាញក្នុសិលាចារឹកសម័យមុនអង្គរ និងអង្គរ ពិសេសសតវត្សទី១១និងទី១២។ ពេលខ្លះវាត្រូវបានបង្ហាញជាឈ្មោះរបស់មនុស្ស។

**១៧.ចេង /Ceṅ/ (រូបលេខ១១៤)**

ចេងជាពាក្យខ្មែរ ដែលអាចមានន័យសំដៅលើប្រភេទភាជន៍ម្យ៉ាង។ យើងមិនទាន់ដឹងរូបរាងពិតប្រាកដរបស់ភាជន៍នេះទេ តែយើងដឹងតាមរយៈសិលាចារឹកថាភាជន៍ប្រភេទនេះភាគច្រើនគេប្រើសម្រាប់ដាក់កំបោរ ឬស្លា។ ពាក្យចេងនេះមានពីរបីដងក្នុងសិលាចារឹកសតវត្សទី៩និងទី១០។

**១៨.ចេហ /Ceh/ (រូបលេខ១១៥)**

ចេហជាពាក្យខ្មែរមានន័យសំដៅលើភាជន៍មួយប្រភេទ ហើយវាស្រដៀងនិងពាក្យចាមហៅថា ចៃហ មានន័យថាភាជន៍។ រូបរាងរបស់វានៅមិនទាន់បានដឹងច្បាស់នៅឡើយទេ។ ប៉ុន្តែពាក្យនេះវាមានសូរដូចពាក្យបច្ចុប្បន្ន ចៃ ដែលមានន័យជាសត្វមាន់ឈ្មោលតូចស្អាត ដែលយើងហៅថា មាន់ចៃ។ ម៉្យាងទៀត យើងបានជួបប្រទះភាជន៍មួយចំនួនដែលមានរូបរាងជាមាន់ឈ្មោល ដូចនេះយើងអាចសន្និដ្ឋានបណ្តោះអាសន្នថា ចេហជាភាជន៍រូបមាន់។

**១៩.ចោក /Cok/ (រូបលេខ១១៦)**

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

AMS អរិយធម៌ខ្មែរ

ចោកជាពាក្យខ្មែរ មានន័យជាភាជន៍ ឬចានគោមតូចមួយប្រភេទ ហើយសព្វថ្ងៃនេះគេស្គាល់និងហៅថា ពែងចក។ រូបរាងរបស់ភាជន៍នេះគឺមានទំហំតូច ក្អែងជាស៊ីឡាំង មាត់ធំ និងបាតរួម។ យើងឃើញមានក្នុងសិលាចារឹកសម័យអង្គរ សតវត្សទី១០ និងទី១២។

**២០.ច្នង/ឆ្នាង /Cnaṅ, Chnāṅ/ (រូបលេខ១៧)**

ច្នងជាពាក្យខ្មែរមានន័យថាជាភាជន៍ប្រើសម្រាប់ចម្អិន។ ភាជន៍នេះមានបាតមូល ក្អែងធំ មាត់តូច ហើយភាគច្រើនមានគម្រប។ វាមានបង្ហាញក្នុងសិលាចារឹកសម័យមុនអង្គរ និងអង្គរ ដែលពេលខ្លះត្រូវបានបង្ហាញថាជាភាជន៍ធ្វើពីសំរឹទ្ធ។

**២១.តន្លប/តន្លាប /Tanlap, Tanlāp/ (រូបលេខ១៨)**

តន្លបជាពាក្យខ្មែរ មានន័យសំដៅលើភាជន៍តូចមានគម្រប ហើយក្លាយមកពាក្យខ្មែរបច្ចុប្បន្នហៅថា ដន្លាប់។ ភាជន៍នេះមានរាងតូចល្មម ក្អែងមូល ឬស៊ីឡាំង និងមានគម្រប គេប្រើសម្រាប់ដាក់ក្រមួន ប្រេងម្សៅ ឬវត្ថុមានតម្លៃផ្សេងៗ។

**២២. ថាស /Thās/**

ថាសជាពាក្យខ្មែរ ជាភាជន៍មួយប្រភេទមានរាងសំប៉ែតធំ ប្រើសម្រាប់ទ្រចាន ពែងជាដើម។ លោកស្រីពៅ សាវរស់គិតថា ពាក្យនេះជាពាក្យអូស្ត្រូនេស៊ី។ ក្នុងសិលាចារឹកបុរាណ ថាសច្រើនធ្វើអំពីលោហៈ ដូចជាសំរឹទ្ធ ឬទង់ដែង។

**២៣.ទីបធារ /Dīpathāra/ (រូបលេខ២០)**

ធីបធារ ជាពាក្យសំស្ក្រឹតមានន័យថា ជាភាជន៍ទៀន គឺមានន័យដូចនិងពាក្យខ្មែរហៅថា ជើងទៀន។ វាមានទំហំតូចល្មម មានជើងបញ្ឈរខ្ពស់បន្តិច និងមានកំណល់នៅកណ្តាលសម្រាប់ទ្រក្រណាត់ឬសសៃអំបោះពេលដុត។ ពាក្យនេះបង្ហាញតែក្នុងសិលាចារឹកសម័យអង្គរ។

**២៤.ទ្លហ /Dlas/**

អ្នកស្រី ពៅ សាវរស់គិតថា ទ្លហជាភាជន៍ធ្វើពីលោហៈប្រើសម្រាប់ចម្អិនម្ហូប។ រូបរាងដើមរបស់ពាក្យនេះនៅមិនទាន់ដឹងច្បាស់នៅឡើយទេ។ សិលាចារឹកភាគច្រើនបង្ហាញ

ថាភាជន៍ប្រភេទនេះធ្វើពីដីដុត លើកលែងតែសិលាចារឹកសតវត្សទី១២មួយ K.366 បង្ហាញពីភាជន៍ប្រភេទនេះធ្វើពីទង់ដែង។

**២៥.នូ/នុ /Nū, nu/ (រូបលេខ២១)**

នូ ជាពាក្យខ្មែរមានន័យថាជាភាជន៍តូចម្យ៉ាង តែរូបរាងពិតប្រាកដរបស់វានៅមិនទាន់ដឹងច្បាស់នៅឡើយទេ។ វាអាចជាប្រភេទថូម្យ៉ាង ព្រោះជារឿយៗយើងឃើញគេប្រើពាក្យនេះជាមួយនិងពាក្យ វេង (ពែង)។ ពាក្យនេះមានតែក្នុងសិលចារឹកសម័យអង្គរ។

**២៦.នោង /Noṅ/ (រូបលេខ២២)**

នោងជាពាក្យខ្មែរ ដែលមានន័យសំដៅលើភាជន៍មានរាងដូចផ្លែឃ្លោក ហើយវាស្រដៀងគ្នានិងពាក្យមន នុង ដែលមានន័យថាភាជន៍សម្រាប់ដាក់ទឹក។ តាមលក្ខណៈជាក់ស្តែង ភាជន៍នេះមានបាតរាបស្មើ ក្អេង២ជាន់ ករាងសុ ីឡាំងស្ដួចឡើងលើ។ ភាជន៍ខ្លះមានលម្អជារូបមនុស្សផងដែរ។ ពាក្យនេះមានក្នុងសិលាចារឹក K.262 ម្តងគត់ បង្ហាញថាជាភាជន៍មកពីចិន (នោងចិន)។

**២៧.បតុល /Patula/ (រូបលេខ២៣)**

អ្នកស្រី ពៅ សាវរស់គិតថា បតុល គឺប្រហែលជាពាក្យខ្មែរមានន័យសំដៅលើភាជន៍មួយប្រភេទ តែមិនច្បាស់អំពីរូបរាងឡើយ។ ខ្ញុំគិតថា ពាក្យនេះអាចក្លាយមកពាក្យសម័យថ្មីហៅថា ផ្តិល ហើយបើក្នុងករណីនេះ បតុល អាចជាភាន៍មានរាបកោង ជួនកាលស្មើ និងក្អេងត្រង់ទដល់មាត់។ ពាក្យនេះមានបង្ហាញខ្លះនៅក្នុងសិលាចារឹកសម័យអង្គរ។

**២៨.បទិគ្រហ/បទិគហ /Padigraha, Padigah/**

បទិគ្រហជាពាក្យសំស្ក្រឹត រីឯបទិគហជាភាសាប្រាក្រឹត ដែលពាក្យទាំងពីរនេះមានន័យថាជាកន្ថោរមួយប្រភេទ។ រូបរាងពិតរបស់ភាជន៍នេះនៅមិនទាន់បានដឹងច្បាស់ទេ ប៉ុន្តែក្នុងករណីជាកន្ថោរ និងតាមរយៈភាជន៍ខ្មែរ វាអាចមានរូបរាងជាភាជន៍ធំល្មម មានបាតរាបស្មើ ជួនកាលជាជើងខ្ពស់ថ្នាក់ៗ ក្អេងធំ កតូចបន្តិច និងមាត់បើករីកចេញក្រៅ។ ពាក្យនេះមានប្រើតិចតួចក្នុងសម័យមុនអង្គរ តែមានច្រើនក្នុងសតវត្សទី១០និង១១។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

២៩.បាត្រ /Pātra/ (រូបលេខ២២៤)

បាត្រជាពាក្យសំស្ក្រឹតមានន័យថាជាចានក្រឡោមមួយប្រភេទ ប្រើសម្រាប់ដាក់ទឹកផឹក។ ក្រោយមកវាក្លាយជាពាក្យខ្មែរ ហើយប្រើសម្រាប់បាយឬចង្ហាន់ព្រះសង្ឃក្នុងពុទ្ធសាសនា។ ភាជន៍នេះមានបាតមូលក្រឡោម ក្អេងប៉ោង មាត់រួមចូលក្នុង មានគម្រប និងជើងដាច់ដោយឡែក។ ពាក្យនេះកម្រមានបង្ហាញក្នុងសិលាចារឹកបុរាណណាស់។

៣០.បាទ្យ /Pādya/ (រូបលេខ២២៥)

ពាក្យសំស្ក្រឹតបាទ្យមានន័យថាជាភាជន៍ឬវត្ថុសម្រាប់ដាក់ទឹកលាងជើង ពិសេសសម្រាប់លាងជើងអោយភ្ញៀវ។ រូបរាងពិតរបស់ភាជន៍នេះនៅមិនទាន់ដឹងច្បាស់នៅឡើយទេ តែអាចមានរាងដូចក្នុងរូបលេខ២២៥។ ពាក្យនេះមានបង្ហាញច្រើនក្នុងសិលាចារឹកសតវត្សទី១០ ទី១១ និងទី១២។

៣១.វរធណី /Vardhaṇī/

វរធណីជាភាសាសំស្ក្រឹតដែលមានន័យជាភាជន៍មួយប្រភេទប្រើសម្រាប់ដាក់ទឹក។ រូបរាងពិតប្រាកដរបស់ភាជន៍នេះនៅមិនទាន់ដឹងច្បាស់នៅឡើយទេ។ ពាក្យនេះមានក្នុងសិលាចារឹកសតវត្សទី១០ ទី១១ និង១២ ជាវត្ថុអំណោយដល់ទីប្រាសាទ។

៣២. វាង/វាញ /Vāṅ, Vāñ/ (រូបលេខ២២៦)

វាងឬវាញជាពាក្យខ្មែរ មានន័យប្រហែលជាភាជន៍ធំមួយប្រើសម្រាប់ដាក់ទឹក ហើយក្លាយមកជាពាក្យសម័យថ្មីហៅថា ពាង។ វាងជាភាជន៍ធំ មានបាតរាបស្មើ ក្អេងប៉ោងធំ និងមាត់រីកចំហ។ ពាក្យនេះមានក្នុងសិលាចារឹកទាំងសម័យមុនអង្គរនិងអង្គរ ចួនកាលជាឈ្មោះរបស់មនុស្សផងដែរ។

៣៣.វាន /Vān/ (រូបលេខ២២៧)

អ្នកស្រីពៅ សាវរស់យល់ថា វាជាពាក្យចិន មានន័យថាជាប្រភេទចានសំប៉ែតមួយបែប។ ពាក្យនេះក្លាយមកជាពាក្យសម័យថ្មីហៅថា ពាន ដែលជាភាជន៍មានសណ្ឋានជាចានសំប៉ែត ក្អេងត្រង់ និងមានជើងទ្រ។ ពាក្យនេះមានម្ដងក្នុងសិលាចារឹកសម័យមុនអង្គរ និងមានច្រើនក្នុងសិលាចារឹកសម័យអង្គរ។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

**៣៤.វៅទិ/វោទិ /Vaudi, Vodi/ (រូបលេខ២២៨)**

វោទិជាពាក្យខ្មែរ មានន័យសំដៅលើភាជន៍ធំម្យ៉ាងមានត្រចៀក ហើយអាចក្លាយមកជាពាក្យខ្មែរទំនើបហៅថា ប៉ោត ដែលមានន័យថាជាប្រភេទធុងម្យ៉ាង។ វាមានរូបរាងជាភាជន៍ធំ មានបាតរាបស្មើ ដួនកាលមានជើងបន្តិច ក្អេងធំទ្រវែង រីកត្រង់ស្មា រួមក និងរីកចេញក្រៅនៅផ្នែកមាត់។ ពាក្យនេះមានក្នុងសិលាចារឹកសម័យមុនអង្គរនិងអង្គរ។

**៣៥.ស្ថាលិ /Sthāli/**

ស្ថាលិជាពាក្យសំស្ក្រឹត ដែលមានន័យថាភាជន៍ប្រើសម្រាប់ចម្អិន ឬជាប្រភេទខ្ទះ។ រូបរាងរបស់វានៅមិនទាន់ដឹងច្បាស់ តែយើងអាចសន្និដ្ឋានថាវាមានអាចជាភាជន៍មានរាងដូចឆ្នាំ គឺមានបាតមូលក្រឡោម ក្អេងត្រង់ទៅលើ និងមាត់ចំហធំ ដួនកាលមានដៃសម្រាប់កាន់ដែរ។ ពាក្យនេះមានម្តងក្នុងសិលាចារឹកសតវត្សទី១១។

**៣៦.ស្វោក/ស្វៅក /Svok, Svauk/ (រូបលេខ២២៩)**

ស្វោកជាពាក្យខ្មែរ មានន័យថាចានសំប៉ែតធំ ឬថាសមួយប្រភេទប្រើសម្រាប់ទ្រចានម្ហូបអាហារ។ សម័យបច្ចុប្បន្ន វាជាប្រភេទភាជន៍ដែលធ្វើអំពីឈើ ជាថាសមានបាតរាបស្មើ ក្អេងត្រង់ខ្លី និងមានគម្របរាងសាជី។ ក្នុងសិលាចារឹកបុរាណ ស្វោកត្រូវបានបង្ហាញជាភាជន៍ធ្វើពីលោហៈ ដូចជាទង់ដែងជាដើម។

**៣៧.សរាវ/សរាវណ /Sarāva, Sarāvaṇa/**

សរាវគឺជាពាក្យសំស្ក្រឹតមានន័យថាចានសំប៉ែតធំមួយប្រភេទ ឬជាប្រភេទភាជន៍ធំម្យ៉ាងធ្វើពីលោហៈមានរូបរាងផ្សេងៗគ្នា។ វាក្លាយមកជាពាក្យខ្មែរសម័យថ្មីហៅថា ស្រាប ឬក៏រាជស័ព្ទ ព្រះស្រាប។ ក្នុងករណីនេះ វាជាភាជន៍មួយមានរាងស្រដៀងគ្នានិងជើងពានដែលមានសណ្ឋានជាចានសំប៉ែត និងមានជើងទម្រ។ ពាក្យនេះមានក្នុងសិលាចារឹកសម័យអង្គរ ភាគច្រើនជាភាជន៍ធ្វើពីលោហៈ ដូចជាប្រាក់ និងសំរឹទ្ធជាដើម។

សរុបសេចក្តីមក តាមរយៈការសិក្សាជាលើកដំបូងនេះ យើងអាចនិយាយបានថាសិលាចារឹកខ្មែរសម័យបុរាណមានសារសំខាន់ និងផលប្រយោជន៍ក្នុងការយល់ដឹងអំពីកុលាលភាជន៍ និងភាជន៍ធ្វើពីលោហៈផ្សេងៗរបស់ខ្មែរ។ តាមរយៈវាក្យស័ព្ទនីមួយៗ យើង

ក៏អាចធ្វើចំណាត់ថ្នាក់លើនានាភាពនៃភាជន៍ទាំងប្រភេទឬរូបរាង ទោះជារូបរាងពិតប្រាកដរបស់ភាជន៍មួយចំនួននៅមិនទាន់អាចស្គាល់ច្បាស់ក៏ដោយ។ ជាបណ្ដោះអាសន្នពាក្យជិត៤០ ទាំងភាសាខ្មែរនិងសំស្ក្រឹត យើងអាចស្គាល់ថា ជាពាក្យដែលត្រូវបានខ្មែរនាសម័យបុរាណប្រើប្រាស់សម្រាប់សម្គាល់និងហៅចំពោះភាជន៍ដែលមានរូបរាងផ្សេងៗគ្នា។ ក្នុងនោះពាក្យមួយចំនួន ដោយការសិក្សាប្រៀបធៀបនិងពាក្យសម័យថ្មី យើងអាចស្គាល់ពីរូបរាងរបស់ភាជន៍បាន។ ក្រៅពីនេះ យើងអាចដឹងពីភាជន៍មួយចំនួនដែលអាចនាំចូលពីបរទេស ដូចជា ឥណ្ឌា និងចិនជាដើម។

## ឯកសារយោង


Baptiste, P., and T. Zéphir, eds. 2005. *Trésors d'art du Vietnam: La sculpture du Champa, Ve–XVe siècles*. Paris: Réunion des musées nationaux and Musée national des arts asiatiques-Guimet.

Barth, A., and M. A. Bergaigne. 1885. *Inscriptions sanscrites du Cambodge et de Campā.* Fac. 1. Paris: Imprimerie Nationale.

Bergaigne, M.A. 1893. *Inscriptions sanscrites du Cambodge et de Campā*. Fac. 2. Paris: Imprimerie Nationale.

Black, J., and G. Coedès. 1953. The inscriptions of Khao Prah Vihār. *Journal of the Siam Society* 47(1):1–58.

Chuan, N. 1967–68. *Vacanānukram Khmaer* [Dictionnaire Cambodgien]. Vols. 1–2. Phnom Penh: Buddhasāsanapandity.

Coedès, G. 1913. Etudes Cambodgiennes VII : La stèle de Pàlhàl. *Bulletin d'École Français d'Extrême-Orient* 13:1–36.

Coedès, G. 1928. Etudes Cambodgiennes LXXXI: Inscription de Tuol Komnap Tā Kin. *Bulletin d'École Français d'Extrême-Orient* 28:81–146.

Coedès, G. 1936. Etudes Cambodgiennes XXXI. *Bulletin d'École Français d'Extrême-Orient* 36:1–21.

Coedès, G., ed. and trans. 1937. *Inscription du Cambodge.* Vol. 1. Hanoi: Imprimerie d'Extrême-Orient.

Coedès, G., ed. and trans. 1942. *Inscription du Cambodge*, Vol. 2. Hanoi: Imprimerie d'Extrême-Orient.

Coedès, G. 1943. Etudes Cambodgiennes XXXVI–XXXVIII. *Bulletin d'École Français d'Extrême-Orient* 43:1–16.

Coedès, G., ed. and trans. 1951. *Inscription du Cambodge*. Vol. 3. Paris: E. de Boccard.

Coedès, G., ed. and trans. 1952. *Inscription du Cambodge*. Vol. 4. Paris: E. de Boccard.

Coedès, G., ed. and trans. 1953. *Inscription du Cambodge.* Vol. 5. Paris: E. de Boccard.

Coedès, G., ed. and trans. 1954. *Inscription du Cambodge.* Vol. 6. Paris: E. de Boccard.

Coedès, G., ed. and trans. 1964. *Inscription du Cambodge*. Vol. 7. Paris: École Français d'Extrême-Orient.

Coedès, G., and P. Dupont. 1943–46. Les stèles de Sdōk Kăk Thom, Phnom Sandak et Práh Vihăr. *Bulletin d'École Françaisd'Extrême-Orient* 43:56–154.

Cort, L. 2000. Khmer stoneware ceramics. In *Asian traditions in clay: The Hauge gifts,* ed. L.

Cort, M. Farhad, and A. Gunter, 90–145: Freer Gallery of Art and Arthur M. Sackler Gallery, Smithsonian Institution.

Finot, L. 1928. Nouvelles inscription du Cambodge. *Bulletin d'École Français d'Extrême-Orient* 38:43–80.

Groslier, B.P, 2000, *Introduction to the Ceramic Wares of Angkor*, in Udaya, No 1, Phnom Penh, pp155-198.

Guy, J. 1989. *Ceramic traditions of South-East Asia*. London and Singapore: Oxford University Press.

Jacques, C. 1970. Etudes d'épigraphie cambodgienne. *Bulletin d'École Français d'Extrême-Orient* 57:57–89.

Jenner, P. N. 1980. *Dated inscriptions from the seventh to eighth centuries.* Hawaii: privately.

Jenner, P. N. 1982. *Lexicon of the undated inscriptions*. Honolulu: Southeast Asian Studies, Center for Asian and Pacific Studies, University of Hawaii.

ឡុង សៀម,២០០០, វចនានុក្រមខ្មែរបុរាណតាមសិលាចារឹកបុរេអង្គរសតវត្សទី៦ ៨, មូលនិធិតូយ៉ូតាប្រទេសជប៉ុន, ភ្នំពេញ។

Martin-Dubost, P. 1997. *Ganeśa: L'enchanteur des trois mondes.* Project for Indian Cultural Studies, ser. 6. Mumbai: Project for Indian Cultural Studies.

Monier-Williams, M. 1956. *A Sanskrit-English dictionary: Etymologically and philologically arranged with special reference to cognate Indo-European languages*. Oxford: Clarendon Press.

Pou, S. 1992. *An Old Khmer-French-English dictionary*. Paris: Centre de Documentation et la Recherche sur la civilization Khmère.

Pou, S., trans. and ed. 2001. *Nouvelles inscriptions du Cambodge*. Paris: École Français d'Extrême-Orient.

Roxanna M. Brown, 2000, *The Ceramics of South-East Asia*:Their Dating and Identification, 2nd Ed.-Art Media Resource-Chicago.

Shorto, H. L. 1971. *A dictionary of Mon inscriptions from the sixth to the sixteenth centuries by H. L. Shorto; Incorporating materials collected by the late C. O. Blagdon*. London and New York: Oxford University Press.

សុខ កែវ សុវណ្ណារ៉ា, ២០០៣, កុលាលភាជន៍ឡូសរសី, សារណាបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា, (២០២១), លក្ខណៈទូទៅនៃកុលាលភាជន៍ខ្មែរសម័យអង្គរ,ក្នុង AMS, ភ្នំពេញ។

Sok Keo Sovannara, 2007, *Rethinking Khmer Ceramics and Metal Vessels through Ancient Inscriptions and Bas-Reliefs: Khmer Ceramic Typology through Ancient Words*, in Scientific Research on Historic Asian Ceramics, Smithsonian Institution, Washington D.C.

Sok Keo Sovannara, 2008, *Recent Survey to Some Historical and Kiln Sites*, FOKCI, Siem Reap.

Southeast Asian Cramics Museum, 1989, *Khmer Ceramics from the Kamratan Collection*, Ktyoto.

Sotheara, V., C. Sokunthy, M. Sovannak, and M.C. Ragavan. 2002. *Ancient inscriptions of Cambodia.* Vols. 1–3. Phnom Penh: UNESCO , in collaboration with the Japanese Trust Fund for the Preservation of World Cultural Heritage.

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

Stchoupak, N., L. Nitti, and L. Renou. 1959. *Dictionnaire Sanskrit-français*. Paris: Librairie d'Amerique et d'Orient, Adrien Maisonneuve.

# បញ្ជីរូបភាព និងប្រភព

រូបលេខ១៖ ភាជន៍មានស្រទាប់រលោងពណ៌ត្នោត (Arthur M. Sackler Gallery, Smithsonian Institution, gift of Osborne and Gratia Hauge, S1996.115)

រូបលេខ២៖ ចម្លាក់ថែវខាងក្រៅ ផ្នែកខាងកើត ស្លាបខាងត្បូង ប្រាសាទបាយ័ន្ត (រូបថតអ្នកនិពន្ធ)

រូបលេខ៣៖ ភាជន៍មានស្រទាប់រលោងពណ៌ត្នោត (Arthur M. Sackler Gallery, Smithsonian Institution, gift of Osborne and Gratia Hauge, S1996.117)

រូបលេខ៤៖ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ៥៖ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ៦៖ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ៧៖ ភាជន៍មានស្រទាប់រលោងពណ៌បៃតងលឿង (Groslier 2000)

រូបលេខ៨៖ ភាជន៍មានស្រទាប់រលោងពណ៌ត្នោត (Arthur M. Sackler Gallery, Smithsonian Institution, gift of Osborne and Gratia Hauge, S1996.118)

រូបលេខ៩៖ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ១០៖ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ១១៖ គំនូរគូរដោយអ្នកនិពន្ធ

រូបលេខ១២៖ ភាជន៍មានស្រទាប់រលោងពណ៌បៃតង (Arthur M. Sackler Gallery, Smithsonian Institution, gift of Osborne and Gratia Hauge, S1996.145)

រូបលេខ១៣៖ ភាជន៍មានស្រទាប់រលោងពណ៌បៃតង (Arthur M. Sackler Gallery, Smithsonian Institution, gift of Osborne and Gratia Hauge, S1996.128)

រូបលេខ១៤៖ ភាជន៍មានស្រទាប់រលោងពណ៌បៃតង (Guy, 1989)

រូបលេខ១៥៖ ភាជន៍មានស្រទាប់រលោងពណ៌ត្នោត (Southeast Asian Ceramic Museum, 1989)

រូបលេខ១៦៖ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ១៧៖ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ១៨៖ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ១៩៖ ចម្លាក់ថែវខាងត្បូង ស្លាបខាងលិច ប្រាសាទអង្គរវត្ត (រូបថតអ្នកនិពន្ធ)

រូបលេខ២០៖ ភាជន៍មានស្រទាប់រលោងពណ៌បៃតង (Groslier, 2000)

រូបលេខ២១៖ ភាជន៍មានស្រទាប់រលោងពណ៌ត្នោត (Roxanna, 2000)

រូបលេខ២២៖ ភាជន៍មានស្រទាប់រលោងពណ៌បៃតង (Arthur M. Sackler Gallery, Smithsonian Institution,

gift of Osborne and Gratia Hauge, S1996.110)

រូបលេខ២៣ៈ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ២៤ៈ គំនូរគូរដោយអ្នកនិពន្ធ

រូបលេខ២៥ៈ ភាជន៍មានស្រទាប់រលោងពណ៌ត្នោត (Roxanna, 2000)

រូបលេខ២៦ៈ ភាជន៍ឡសរសី (សុខ កែវ សុវណ្ណារ៉ា ២០០៣)

រូបលេខ២៧ៈ ភាជន៍ផុយនៅសារមន្ទីរអង្គរបុរី (Sok, 2008)

រូបលេខ២៨ៈ ចម្លាក់ប្រាង្គខាងជើងប្រាសាទនាគព័ន្ធ (សុខ កែវ សុវណ្ណារ៉ា, ២០០៣)

រូបលេខ២៩ៈ ចម្លាក់ថែវខាងក្នុង ផ្នែកខាងជើង ស្លាបខាងកើត ប្រាសាទបាយ័ន្ត (រូបថតអ្នកនិពន្ធ)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា



រូបលេខ១-អាង



រូបលេខ២-កទាហ



រូបលេខ៣-កថោរ



រូបលេខ៤-កន្ទិន



រូបលេខ៥-កន្លោ



រូបលេខ៦-កមណ្ឌលុ



រូបលេខ៧-ករងក



រូបលេខ៨-កន្ដិ



រូបលេខ៩-កុសុម្ភ



រូបលេខ១០-កោស



រូបលេខ១១-ខាល



រូបលេខ១២-ក្លៀង



រូបលេខ១៣-ចាន

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២១៤-ចេង



រូបលេខ២១៥-ចេហ



រូបលេខ២១៦-ចោក



រូបលេខ២១៧-ថ្នាង



រូបលេខ២១៨-តន្លប



រូបលេខ២១៩-ថាស



រូបលេខ២២០-ធឹបធារ



រូបលេខ២២១-នូ



រូបលេខ២២២-នោង



រូបលេខ២២៣-បតុល



រូបលេខ២២៤-បាត្រ



រូបលេខ២២៥-បាទ្យ



រូបលេខ២២៦-រាំង



រូបលេខ២២៧-វ៉ាន



រូបលេខ២២៨-វៅទិ



រូបលេខ២២៩-ស្មោក

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា